まんがでわかる

# フォークリフトの安全衛生

ភាសាខ្មែរ
クメール語

## ស្វែងយល់តាមរយៈគំនូរជីវចល សុវត្ថិភាពអនាម័យនៃឡានចូកទំនិញ




វីដេអូនេះត្រូវបានរៀបរៀងឡើងដើម្បីឲ្យអ្នក ធ្វើការនៅកន្លែងការងារដែលប្រើប្រាស់ឡានចូកទំនិញ
អាចសិក្សាពីមូលដ្ឋាននៃសុវត្ថិភាពនិងអនាម័យ។







## ចំនួនអ្នកស្លាប់និងរបួសដោយសារគ្រោះថ្នាក់ការងារ

| | | |
|---|---|---|
| 1 | ត្រូវបានបុក (រួមទាំងការបុកត្រូវ) | 816 នាក់ |
| 2 | ត្រូវបានគាប/ត្រូវបានទាក់ចូល | 769 នាក់ |
| 3 | ធ្លាក់/ដួល | 424 នាក់ |
| 4 | ខ្ទាត/ធ្លាក់មកពីលើ | 107 នាក់ |
| 5 | រអិលដួល | 102 នាក់ |

យោង៖ ស្ថានភាពគ្រោះថ្នាក់បណ្ដាលឲ្យស្លាប់ឬរបួសយោងតាម «របាយការណ៍ស្លាប់ឬរបួសរបស់ពលករ»នៃក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព H៣១/R១ (ខែឧសភា ឆ្នាំ២០២០)


មែនហើយ។
ដំបូងយើងមើលគ្រោះថ្នាក់«ត្រូវបានបុក (រួមទាំងការបុកត្រូវ)»។
«ការបុក» គឺជាគ្រោះថ្នាក់ដូចជា ឡានចូកទំនិញដែលកំពុងបរនោះ ទៅប៉ះនឹងជញ្ជាំង។
រីឯ«ត្រូវបានបុក»គឺជាគ្រោះថ្នាក់ ដូចជាអ្នកធ្វើការនៅជុំវិញ ត្រូវបានឡានចូកទំនិញបុកត្រូវ។
ឡានចូកទំនិញធ្ងន់ណាស់ បើបុកត្រូវពិតជាគ្រោះថ្នាក់មែន។
លើសពីនេះទៀត ឡានចូកទំនិញ មានល្បឿនលឿនផង ដូច្នេះត្រូវប្រុងប្រយ័ត្ន។


ធ្វើម៉េចទើបអាច ការពារបាន?
ប្រាកដណាស់ថា អ្នកបើកបរត្រូវប្រុងប្រយ័ត្ន តែអ្នកធ្វើការនៅជុំវិញក៏ត្រូវដឹងពី ការធ្វើចលនារបស់ឡានចូកទំនិញដែរ។
អូ យល់ហើយ។
ប៉ុន្តែ ជាមូលដ្ឋាន អ្នកបើកបរត្រូវប្រយ័ត្នសិនមែនទេ?
ហា?
មិនមែនតែ អ្នកបើកបរទេ អ្នកធ្វើការនៅជុំវិញ ក៏ត្រូវប្រយ័ត្នដែរ!
ចា ចាំ!


បន្ទាប់មកគឺគ្រោះថ្នាក់«ត្រូវបានគាប/ត្រូវបានទាក់ចូល»។ ឡានចូកទំនិញមានផ្នែកធ្វើចលនាច្រើន ដូច្នេះច្រើនមានគ្រោះថ្នាក់ត្រូវបានគាប។
ដោយឡែក ក៏មានករណីត្រូវបានគាបនៅចន្លោះជញ្ជាំង និងឡានចូកទំនិញដែលកំពុងថយក្រោយដែរ។
ប្រសិនបើរងរបួសធ្ងន់មិនអាចធ្វើការបាន ធ្វើឲ្យគ្រួសារបារម្ភផង ហើយផ្នែកសេដ្ឋកិច្ចក៏លំបាកដែរ...។
ដូច្នេះហើយចាំបាច់ត្រូវយល់ច្បាស់ពីខ្លឹមសារមេរៀន និងគោរពវិន័យ។
ត្រូវយល់ពីវិធីប្រើប្រាស់ត្រឹមត្រូវតាមមេរៀនដែលបានរៀន និងប្រើឲ្យបានត្រឹមត្រូវ។
ម្យ៉ាងទៀត ការយល់ពីរបៀបធ្វើចលនារបស់ឡានចូកទំនិញក៏សំខាន់ដែរ។


តើការ«ធ្លាក់/ដួល» មានគ្រោះថ្នាក់ការងារបែបណាខ្លះ?
ឧទាហរណ៍ដូចជាធ្វើរឿងដែលមិនត្រូវធ្វើ
ដូចជាករណីឲ្យមនុស្សជិះលើកន្លែងចូកទំនិញរបស់ឡានចូកទំនិញ ហើយធ្វើការនៅទីខ្ពស់ រួចក៏ធ្លាក់ចុះមក។
គ្រោះថ្នាក់មែន...។
カチッ…
តោះ
ガーッ
おぉっ
ទៅកន្លែងជាក់ស្តែង
1
ពិនិត្យមើល!

# ករណីទី១


ណៃ! តមកទៀតបាឡែកនៅខាងនោះ ពឹងលើឯងហើយ។
បាទ!
ត្រូវត្រឡប់ក្រោយ ហើយ បង្វែទិស។
តែបើ បើកថយ ក្រោយ...
ត្រូវកាច់ចង្កូចត្រង់ណា ដូចជាមិនសូវច្បាស់ ហើយមិន ពូកែទៀត។


ណ្ហើយចុះ បើកបរដោយប្រើ កញ្ចក់ទៅក្រោយក៏បានដែរ។
ធ្វើម៉េចទៅ ប្រើពេលសម្រាប់ត្រៀម អស់ហើយ ជញ្ជូនមិនទាន់ទេ។
មែនហើយ! បើឆ្លងកាត់តាមនេះ អាចចំណេញពេលបាន!
ចាប់ពីខ្សែខាងមុខ ក្រៅពីឡានចូកទំនិញ គេហាម មិនឲ្យចូលទេ...។


ល្អ!
គ្មាននរណានៅទេ។
ឥឡូវឡានចូកទំនិញ
អត់មានចលនាផង
មិនអីទេ។
លោកអើយ!!


ピタッ!!
ម៉េចបានមាន
មនុស្សនៅទីនេះ!?
មិនអីទេ?
មិ មិនអីទេ...។
ម៉េចបានមិនដើរតាម
ផ្លូវសម្រាប់
អ្នកថ្មើជើងចឹង!
សុំទោស...។
ឈប់សិន។


តាមពិត ឯងក៏ត្រូវប្រយ័ត្នដែរ មែនទេ?
មានបានគិតទេថា នឹងមានអ្វីលោតចេញ មកភ្លាមៗ?
ពេលថយក្រោយគឺ មិនត្រូវពឹងតែលើកញ្ចក់ មើលក្រោយទេ!
ត្រូវមើលស្ថានភាពជុំវិញ ដោយផ្ទាល់ភ្នែក!
សុំទោស!!
ខាងក្រោយ អូខេ!
ពេលពិនិត្យបញ្ជាក់ ការប្រើដៃចង្អុលប្រាប់ ក៏សំខាន់ដែរ។

ហើយឯងក៏ត្រូវ គោរពវិន័យកន្លែងការងារ ដូចជាមិនចូលក្នុងតំបន់ ហាមឃាត់ជាដើម!
ពេលឡានចូកទំនិញវិលតិចៗ ស្រាប់តែរំកិលចេញ ដូចលើកនេះ ក៏មានដែរ។
ដូច្នេះហើយ ដាច់ខាតមិនត្រូវនៅក្បែរ ឡានចូកទំនិញទេ!
ម្យ៉ាងទៀត នៅក្នុងឃ្លាំងមានកន្លែងច្រើនណាស់ ដែលអ្នកបើកបរពិបាកមើលឃើញ។
មិនមែនតែអ្នកបើកបរទេ សំខាន់អ្នកធ្វើការ នៅជុំវិញក៏ត្រូវ ប្រយ័ត្នដែរ។
បើមានរបួស នឹងធ្វើឲ្យ ក្រុមគ្រួសារបារម្ភ។
ខ្ញុំនឹងប្រយ័ត្ន...។

# ករណីទី២


ជញ្ជូនអានេះហើយ មើលទៅអាច ចប់ការងារមុនម៉ោង!
អូ... បាឡែត មិនស្មើគ្នាទេ។
មែនហើយ...។
បើដាក់បាឡែត ក្នុងស្ថានភាព មិនស្មើគ្នា
អាចនឹង ធ្វើឲ្យធ្លាក់។


ពេលកែតម្រូវទំនិញ នៅឡានចូកទំនិញ ដាច់ខាតត្រូវទម្លាក់ ប្រដាប់ចូកចុះ!
ហើយត្រូវបិទ កុងតាក់ភ្លើង និងទម្លាក់ ប្រដាប់ចូកចុះ។
OFF
នេះជាអ្វីដែល ត្រូវបានប្រាប់...។
ទម្លាក់ចុះនាំតែសាំញ៉ាំទេ កែតម្រូវបាឡែត ទាំងអញ្ចឹង ហ្មងទៅ។
អូ! ទៅរួចតាស់!


ぐっ
អ៊ា!!
ぐぐぐっ
ឈប់សិន! ប្រដាប់ចូក
ចាប់ផ្ដើមមានចលនា
ហើយ!
ម៉េច ម៉េចនឹង!?
មិនត្រូវកែតម្រូវទំនិញទាំងកំពុង
ជិះលើឡានចូកទំនិញទេ។


ON
មិនបាន
បិទកុងតាក់ភ្លើង។
ហើយមិនទម្លាក់
ប្រដាប់ចូកចុះទៀត។
មិនធ្វើតាមមេរៀនដែល
បានរៀនគឺមិនកើតទេ។
គិតថាវាតិចតួចចឹង
មិនអីទេ...។
បានហើយ លើកនេះ
សំណាងហើយដែលគ្មាន
គ្រោះថ្នាក់...
ប្រសិនបើបណ្ដោយទាំងអញ្ចឹង
ហើយរាងកាយប៉ះត្រូវចង្កឹះលេខ...


ធ្វើឲ្យខ្សែពាន
ប្រដាប់ចូករំកិល
រាងកាយនឹងត្រូវ
បានគាបជាប់
ករណីអាក្រក់បំផុតគឺ
អាចនឹងមានគ្រោះថ្នាក់
បាត់បង់ជីវិតទៀត...។
បើមិនគោរពវិន័យអាចនឹង
បណ្ដាលឲ្យស្លាប់បាន...។
ទីបំផុតដឹងពីភាពធ្ងន់ធ្ងរ
ហើយមែនទេ។


«គ្រាន់តែប៉ុណ្ណឹងវាមិនអីទេ»
ការគិតបែបនេះអាចបង្កឲ្យ
កើតមានគ្រោះថ្នាក់។
គ្មានវិន័យណាដែលមិន
ចាំបាច់គោរពតាមនោះ
ឡើយ។
ខ្ញុំពិតជាសុំទោស
មែន!!
សិស្សច្បង! អរគុណច្រើន
ដែលបានបញ្ឈប់វា!
បងជាអ្នកមានគុណ
ជួយជីវិតខ្ញុំ!
គ្មានរឿងអ្វី
កើតឡើងពិតជា
ប្រសើរណាស់។

# ករណីទី៣


ウィーーン
ដូចជារាងស៊ាំនឹងការបញ្ហាហើយ។
សល់តែដាក់អានោះពីលើទេ។
ぐらぐら
ទំនិញនេះងាយរលំណាស់...។


សុំទោស!
ទំនិញនេះ ធ្វើម៉េចបានវាមិនរលំ។
អូ ឲ្យខ្ញុំជិះលើបាឡែកទេ?
ខ្ញុំអាចទប់ទំនិញលើបាឡែកបាន។
អឺ អានឹងពិបាកដឹកមែន។
ធ្វើចឹងមិនគ្រោះថ្នាក់ទេ?
មិនអីទេ។


លើកឡើងបាន
ហើយ!
ウィイイイーン
បន្តិចទៀត
ぐらっ
រលំហើយ!
អូយ


ឈឺ!!
អត់អីទេ?
អត់អីទេ គ្រាន់តែត្រូវ
ជង្គង់បន្តិច។
ស្មានតែសម្លេងអី ពេល
មកឃើញទើបដឹង!


លើកនេះសំណាង ហើយត្រូវរបួសស្រាល...។
អាស្រ័យតាមកម្ពស់ អាចនឹងបង្កទៅជាគ្រោះថ្នាក់បាត់បង់ជីវិតក៏មានដែរ!
ដើមឡើយ!
តាមវិន័យ ការធ្វើការនៅកន្លែងខ្ពស់ ដោយជិះលើបាឡែក និងប្រដាប់ចូក គឺត្រូវបានហាម!
NG
កម្ពស់ដូចអម្បាញ់មិញ បើក្បាលចុះមកមុន នឹងមានអ្វីកើតឡើង!


ដាច់ខាតមិនត្រូវធ្វើទេ!
សុំទោស។
កុំគិតថាសុវត្ថិភាពគឺជារឿងធម្មតា
ចាំបាច់ត្រូវមានស្មារតីប្រុងប្រយ័ត្នជារៀងរាល់ពេល។
ទំនិញបែបនេះ ពេលដឹកត្រូវយកស្កត់មករុំជាប់គ្នាទៅ ស្រួលដឹកហើយ។
បើជួបបញ្ហាអីសូមពិគ្រោះជាមួយខ្ញុំ។
មិនត្រូវដោះស្រាយដោយខ្លួនឯងទេ។
បាទ!






## ចំណុចត្រូវប្រុងប្រយ័ត្ននៅក្នុងការងារឡានចូកទំនិញ

### 1 | ប័ណ្ណបញ្ចប់ការសិក្សាជំនាញ

ករណីបើកបរឡានចូកទំនិញទម្ងន់ក្រោម១តោន
ត្រូវទទួលការអប់រំពិសេស។



ការបើកបរឡានចូកទំនិញ ចាំបាច់ត្រូវបញ្ចប់ការរៀនជំនាញ។
ម្យ៉ាងទៀត ដាច់ខាតត្រូវយកប័ណ្ណបញ្ចប់ការសិក្សាជាប់ខ្លួន។

### 2 | នៅជុំវិញឡានចូកទំនិញ




ដាច់ខាតសូមកុំទៅក្បែរឡានចូកទំនិញ និងតំបន់ហាមចូល។

### 3 | ត្រូវបានគាប




ទំនិញដែលមាននៅលើឡានចូកទំនិញ
ត្រូវធ្វើការកែតម្រូវដោយចុះពីលើឡានចូកទំនិញ។

### 4 | ធ្លាក់/ដួល




ជាគោលការណ៍ ការដែលឲ្យមនុស្សជិះលើ
ប្រដាប់ចូកនិងបាឡែតគឺត្រូវបានហាមឃាត់។




ការងារឡានចូកទំនិញ

# ចូរប្រុងប្រយ័ត្នចំណុចទាំងនេះ!
# ព័ត៌មានជំនួយដើម្បីសុវត្ថិភាព និងសុខភាព!



**1** ប្រយ័ត្នមានអ្នកលោតចេញពីក្នុងឃ្លាំង!



**2** ប្រយ័ត្នការបើកបរមិននឹងន!



**3** ប្រយ័ត្នការដឹកហួសកម្រិត/ទំនិញរលំ!



**4** ប្រយ័ត្នពេលចត!



វែងយល់តាមរយៈរូបភាព

ស្វែងយល់ពីហានិភ័យបង្កប់ក្នុងកន្លែងធ្វើការ!

# ហ្វឹកហាត់ស្មារតីដឹងមុនពីហានិភ័យ(KYT)

## Q ចូរគិតថាហានិភ័យមាននៅកន្លែងណាខ្លះ!



## A នេះជាចំណុចហានិភ័យ!




1 មិនត្រូវចូលក្នុងតំបន់ហាមឃាត់ឡើយ។



2 មិនឆ្លងកាត់តាមក្រោយឡានចូកទំនិញ។



3 ប្រយ័ត្នចំពោះការដាក់ទំនិញហួសកម្រិត។



4 មិនបង្វិលភ្លាមៗ។



ចូរគិតថាមានចំណុចហានិភ័យផ្សេងទៀតដែរឬទេ។

ស្វែងយល់តាមរយៈគំនូរជីវចល
សុវត្ថិភាពអនាម័យនៃឡានចូកទំនិញ

ចេញផ្សាយខែមីនា ឆ្នាំ២០២១
ចេញផ្សាយដោយ៖ ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព
រៀបចំដោយ៖ Mizuho Information & Research Institute, Inc.
សហការដោយ៖ ក្រុមការងាររៀបរៀងសម្ភារៈអប់រំស្ដីពីសុវត្ថិភាពពាក់ព័ន្ធនឹងវិស័យដឹកជញ្ជូនទំនិញតាមផ្លូវគោគ និងឡានចូកទំនិញ
ផលិតដោយ៖ Sideranch Inc.

厚生労働省
Ministry of Health, Labour and Welfare

កន្លែងទំនាក់ទំនងពាក់ព័ន្ធនឹងឯកសារនេះ

ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព
មន្ទីរស្តង់ដារការងារ
ផ្នែកសុវត្ថិភាពនិងអនាម័យ
ការិយាល័យសុវត្ថិភាព